ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី

លេខ៖ ៣៨៤/១៩.៩.២០១២ បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នាថ្ងៃទី ១៥.១១.២០១២

សាលដីកា

លេខ៖ ៩១ក្រ៤អ/១៥.១១.២០១២

តាងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រម
លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

-ដើមចោទ ឈ្មោះ [redacted] សុភា ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

មេធាវី លោក [redacted] តំណាងដោយអាណត្តិ អោយដើមចោទ ឈ្មោះ [redacted] សុភា ។

-ដើមចោទ ឈ្មោះ [redacted] ផល្លា ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទ ឈ្មោះ [redacted] ល្លី ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទ ឈ្មោះ [redacted] សុភាព ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទ ឈ្មោះ [redacted] វីណា ភេទស្រី អាយុ២៦ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទ ឈ្មោះ [redacted] សុជាវី ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយ ឈ្មោះ [redacted] ជំនោរ ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយ ឈ្មោះ [redacted] ចំណាប់ ហៅ [redacted] ចំណាប់ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយ ឈ្មោះ [redacted] រតនៈ ភេទប្រុស ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយ ឈ្មោះ [redacted] រតនា ភេទប្រុស ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

62/3

-ចុងចម្លើយ ឈ្មោះ [redacted] ធីតា ភេទប្រុស ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយ ឈ្មោះ[redacted] ម៉ូនីកា ភេទស្រី អាយុ២០ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយ ឈ្មោះ[redacted] ហ៊ីម ភេទស្រី ឆ្នាំកំណើត១៩៧០ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន នៅ ភូមិរោងម៉ាស៊ីន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយ ឈ្មោះ[redacted] សុខា ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅ ភូមិភ្នំតូចខាងជើង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយ ឈ្មោះ [redacted] សារ៉ាយ ហៅ [redacted]សម្បត្តិ ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ននៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

<u>កម្មវត្ថុ សុំតុលាការចេញសាលក្រមសម្រេចអំពី៖</u>

១.សុំឲ្យតុលាការបែងចែកឡើងវិញនូវដីកេរ្តិ៍របស់សព ឈ្មោះ [redacted] ហួរ មានទំហំ ១២០៧៩ (មួយម៉ឺនពីរពាន់សូន្យរយចិតសិបប្រាំបួន) ម៉ែត្រការ៉េ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

<u>អង្គហេតុ៖</u>

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០១០ របស់ដើមចោទ ឈ្មោះ[redacted]ផល្លា និងអ៊ីវ សុភា បញ្ជាក់ថាៈ សពឈ្មោះ[redacted] ហួរ មានប្រពន្ធដើមឈ្មោះ [redacted] ហ៊ាប មានកូនប្រាំមួយនាក់ និងប្រពន្ធចុងឈ្មោះ [redacted]ហឿន មានកូនប្រាំមួយនាក់ ។ ការដែលសពលោក[redacted] ហួរ បានរួមរស់នៅជាមួយនិងប្រពន្ធចុងឈ្មោះ[redacted]ហឿន មានដីមួយកន្លែងទំហំ ១២០៧៩ ម៉ែត្រការ៉េ ស្ថិតនៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និងពេលដែលសពលោក អ៊ីវ ហួរ នៅរស់ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០០ បានធ្វើលិខិតផ្ទេរសិទ្ធិដីឲ្យទៅឈ្មោះ[redacted] សារ៉ាយ រួចហើយ នៅក្នុងឆ្នាំ២០០៩ ឈ្មោះ [redacted] ហួរ បានទទួលមរណភាពទៅដោយពុំមានធ្វើមត៌កសាសន៍អ្វីឡើយ ។ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ ភាគីតំណាងឲ្យខាងប្រពន្ធនិងកូនដើម [redacted] សុភា) និងតំណាងឲ្យខាងប្រពន្ធនិងកូនចុង[redacted] ជំនោរ) បានចុះកិច្ចព្រមព្រៀងបែងចែកទ្រព្យជាដីស្រែដែលជារបស់មតកជន ហើយបានព្រមព្រៀងគ្នាថាឈប់ប្តឹងផ្តល់គ្នាចាប់ពីថ្ងៃចុះកិច្ចព្រមព្រៀងនេះតទៅ ស្រាប់តែនៅថ្ងៃ ១៥-៧-២០១១ ចុងចម្លើយក៏បានដាក់ពាក្យបណ្តឹងចូលមកតុលាការ ដើម្បីប្តឹងសុំបែងចែកដីលំនៅឋានទំហំ ១២០៧៩ ម៉ែត្រការ៉េ ដោយសំអាងថាកាលលើកមុនចែកគ្នាតែដីស្រែទេ ។

<u>ចំណុចវិវាទ៖</u>

ដើមចោទនៅតែទាមទារឲ្យបែងចែកដីកេរ្តិ៍របស់[redacted] ហួរ ទំហំ ១២០៧៩ ម៉ែត្រការ៉េ ស្ថិតនៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាពីរចំណែកស្មើរគ្នា គឺដើមចោទយកពាក់កណ្តាលស្មើនិងទំហំ៦០៣៩ម៉ែត្រការ៉េ និងប្រគល់ឲ្យចុងចម្លើយពាក់កណ្តាលស្មើ និង៦០៣៥ ម៉ែត្រការ៉េ តែចុងចម្លើយពុំយល់ព្រមតាមការទាមទាររបស់ដើមចោទ ។

<u>ការអះអាងរបស់គូភាគី៖</u>

៤៦៨

468

-ដើមចោទឈ្មោះ [redacted] សុភា និង [redacted] ផល្លា ជាអ្នកទទួលសិទ្ធិពីបងប្អូនទាំង៤នាក់ទៀត បានធ្វើសេចក្តីថ្លែងហេតុថាៈ ដីទំនាស់នោះ ខ្ញុំមិនអាចអោយគាត់បានទេ ព្រោះដីជាដីមរតករបស់ឪពុកម្តាយខ្លួន ។

សំណូមពរៈ សុំលោកតុលាការចែកដីទំនាស់ជា២ចំណែកស្មើគ្នា ។

-ចុងចម្លើយ ឈ្មោះ [redacted] សារ៉ាយ ហៅ [redacted] សម្បត្តិ បានធ្វើសេចក្តីថ្លែងហេតុថាៈ ខ្ញុំបាទជាអ្នកទទួលសិទ្ធិ តំណាងឲ្យប្អូនទាំង៥នាក់ទៀត ខ្ញុំបាទមានទីលំនៅ២កន្លែង១នៅផ្ទះលេខ ២០៥A ផ្លូវ១៩ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ១ទៀតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ មុខរបរយោធា ។ ឪពុកខ្ញុំឈ្មោះ [redacted] ហួរ ម្តាយឈ្មោះ [redacted] ហឿន ហ [redacted] ណៃ គាត់អត់បានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ នៅក្នុងរបបប៉ុលពត ។ ដីទំនាស់មានលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ១០-៦-២០០០ ខ្ញុំមិនព្រមធ្វើការបែងចែកឲ្យទេ ព្រោះដីនេះជាចំណែកគ្រួសារខ្ញុំ និង ម្តាយខ្ញុំ ដោយម្តាយឪពុកខ្ញុំបានបែងចែកឲ្យមុន ឈ្មោះ [redacted] សុភា និង [redacted] ផល្លា ទាមទារទៅទៀត ។ ខ្ញុំកើតនៅឆ្នាំ១៩៧៣ ។ ម៉ុនីតា កើតនៅថ្ងៃទី ៧-១១-១៩៩១ អ៊ីវ រតនៈ កើតនៅថ្ងៃទី ១៨-៥-១៩៨៦ ។

សំណូមពរៈ សុំលោកតុលាការ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៩ (ខ) ចុះថ្ងៃ ២៧-៦-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកនៅដដែល ។

-លោកមេធាវី [redacted] តំណាងដោយអាណត្តិអោយដើមចោទបានធ្វើសេចក្តីថ្លែងហេតុថាៈ កូនក្តីខ្ញុំឈ្មោះ [redacted] ភា មានឪពុកឈ្មោះ [redacted] ហួរ ម្តាយឈ្មោះ [redacted] ហ៊ាប អ្នកទាំងពីរបានរៀបអាពាហ៍ពិពាហ៍នៅខេត្តកំពង់ធំ មុនជំនាន់ប៉ុលពត បងគេបង្អស់ឈ្មោះ [redacted] ផល្លី ឪពុកកូនក្តីខ្ញុំស្លាប់ នៅថ្ងៃ ៩-៦-២០០៩ កូនក្តីខ្ញុំដឹងថា គាត់មានប្រពន្ធ១ទៀត ឈ្មោះ [redacted] ហឿន ហ អេង ណៃ ។

-មេធាវី លោក [redacted] តំណាងដោយអាណត្តិអោយដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថាៈ ក្នុងរឿងក្តីនេះ កូនក្តីខ្ញុំក៏ជាកូនរបស់លោក [redacted] ហួរ និង ប្រពន្ធ ឈ្មោះ [redacted] ហ៊ាប ជាប្រពន្ធដើម ដូច្នេះ កូនក្តីខ្ញុំក៏មានសិទ្ធិទទួលបាននូវកេរ្តិ៍មរតករបស់លោក អ៊ីវ ហួរ និងប្រពន្ធ ឈ្មោះ [redacted] ហ៊ាប ដែរ ។

សំណូមពរៈ សុំប្រធានក្រុមប្រឹក្សា និង ក្រុមប្រឹក្សាចែកដីទំនាស់នេះជា២ចំណែកស្មើគ្នា និង សុំប្រានចោល នូវសាលក្រមរដ្ឋប្បវេណីលេខៈ ០៩ (ខ) ចុះថ្ងៃ ២៧ មិថុនា ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

## សំអាងហេតុ ៖

-យល់ឃើញថា ៖

១.បណ្តឹងឧទ្ធរណ៍ លេខ ២០ ចុះថ្ងៃ ២៨ មិថុនា ២០១២ របស់ឈ្មោះ [redacted] សុភា ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

-មេធាវី នូ ចន្ថា តំណាងដោយអាណត្តិអោយឈ្មោះ [redacted] សុភា ត្រឹមត្រូវតាមច្បាប់ ។

២.តាមសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខ ០១ ចុះថ្ងៃ ១៤-៦-២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ (ឯ.៣១/៩) បញ្ជាក់ថា ឈ្មោះ [redacted] ហ៊ាប ជាប្រពន្ធរបស់ឈ្មោះ [redacted] ហួ និងតាម សៀវភៅគ្រួសារ លេខ៖ ០២៤១៤៤ ចុះថ្ងៃ ១៦ កក្កដា ២០០៩ (ឯ.៣១/៧) បញ្ជាក់ថា ឈ្មោះ [redacted] ហួរ ជាមេគ្រួសារ ឈ្មោះ [redacted] ហ៊ាប ជាប្រពន្ធមានកូន៦នាក់ ឈ្មោះ [redacted] ផល្លី, [redacted] សុភា, [redacted] សុភាព, [redacted] ផល្លា [redacted] សុជាវី, អ៊ីវ រីណា (សំបុត្របញ្ជាក់កំណើតឯ-៣១/៦-៣១/៥-៣១/៤-៣១/៣-៣១/២-៣១/១) ។

៣.តាមសៀវភៅគ្រួសារ ចុះថ្ងៃ១០-៣-២០០៨ បញ្ជាក់ថា ឈ្មោះ [redacted] ហួរ ជាមេគ្រួសារ និងឈ្មោះ [redacted] ហឿន ជាប្រពន្ធមានកូនបង្កើត៦នាក់ ឈ្មោះ [redacted] ម្បត្តិ [redacted] សារ៉ាយ) [redacted] ចំណាប់- [redacted] រតនា [redacted] តនៈ [redacted] ធីតា- [redacted] មុនីតា (សំបុត្របញ្ជាក់កំណើត ឯ-៣៥/១-៣៦/៥-៣៦/៨-៣៦/៧-៣៦/៤-៣៦/៦) ។



Scanned with CamScanner

(64/1)

ឃើញឈ្មោះ [redacted] ហួរ មានប្រពន្ធ២នាក់ ឈ្មោះ [redacted] ហ៊ាប និង [redacted] ហឿន ហើយមានកូនម្នាក់ៗ ៦នាក់ ។

៤.តាមគំនូសប្លង់ដីទំនាស់ ចុះថ្ងៃ៤ មេសា ២០១២ (ឯ.២៤/២៨) របស់ការិយាល័យ សុរិយោដី និងភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ បញ្ជាក់ថា ដីទំនាស់ ជាប្រភេទដីសាងសង់មានទំហំ ១២០១៦ ម² ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដីនេះមានពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ឈ្មោះ [redacted] ហឿន ប្ដីឈ្មោះ [redacted] ហួរ ចុះថ្ងៃ ២៦-៦-១៩៩០ (ឯ.៤២/៤) ។ ដូចនេះដីនេះជាទ្រព្យរួមរបស់ [redacted] ហឿន និង [redacted] ហួរ ក៏ជាទ្រព្យរួមរបស់ [redacted] ហួរ និង [redacted] ហ៊ាប ដែរ ។

៥.លិខិតប្រគល់សិទ្ធិ ចុះថ្ងៃ ១០ មិថុនា ឆ្នាំ២០០០ (ឯ.៣៨) ឈ្មោះ [redacted] ហួរ និងប្រពន្ធ ឈ្មោះ [redacted] ហឿន ហៅ [redacted] ណៃ បានប្រគល់សិទ្ធិកាន់កាប់ដី និងឃ្លាំងចំនួន២ហត ស្ថិតនៅភូមិទឹកថ្លា ឃុំទឹកថ្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ព្រមទាំងផ្ទះល្វែង៣ល្វែង ស្ថិតនៅពីមុខផ្សារអូរអំបិល អោយទៅឈ្មោះ [redacted] សារ៉ាយ ជាកូនរបស់ឈ្មោះ [redacted] ហួរ និង [redacted] ហឿន ដោយមានស្នាមមេដៃអ្នកប្រគល់ ឈ្មោះ [redacted] ហឿន និង ឈ្មោះ [redacted] ហួរ ផង ។ ឃើញថាការប្រគល់សិទ្ធិលើអចលនទ្រព្យ ដែលជាសហកម្មសិទ្ធិ មិនត្រឹមត្រូវតាមច្បាប់ដោយសហព័ទ្ធ ឈ្មោះ [redacted] ហ៊ាប មិនបានព្រមព្រៀង ។ ដូចនេះគប្បីលុបចោល លិខិតប្រគល់សិទ្ធិ ចុះថ្ងៃ ១០ មិថុនា ២០០០ ចោល ។ យកដីទំនាស់បែងចែក ជាពីរចំណែកស្មើគ្នាឲ្យ ដើមចោទ និងចុងចម្លើយ ។

៦.សាលក្រមរដ្ឋប្បវេណី លេខ ០៩ (ខ) ចុះថ្ងៃ ២៧ មិថុនា ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ពុំមានលក្ខណៈត្រឹមត្រូវគប្បីលុបចោល ។

**ហេតុដូចនេះ វិនិច្ឆ័យសេចក្តី**

១.លុបចោលសាលក្រមរដ្ឋប្បវេណី លេខ ០៩ (ខ) ចុះថ្ងៃ ២៧ មិថុនា ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២.លុបចោលលិខិតប្រគល់សិទ្ធិ ចុះថ្ងៃ ១០ មិថុនា ២០០០ ។

៣.ដីទំនាស់ស្ថិតនៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទំហំ ១២០១៦ ម² តាមគំនូសប្លង់ដីទំនាស់ ចុះថ្ងៃ ៤ មករា ២០១២ របស់ការិយាល័យសុរិយោដី និងភូមិសាស្ត្រ ត្រូវបែងចែកជាពីរចំណែកស្មើគ្នា អោយទៅដើមចោទឈ្មោះ [redacted] សុភា- [redacted] ផល្លា- [redacted] ផល្លី - [redacted] សុភាព- [redacted] ណា [redacted] សុធារី មួយចំណែក និងមួយចំណែកទៀតអោយទៅឈ្មោះ [redacted] សារ៉ាយ ហៅ [redacted] សម្បត្តិ- [redacted] បុខា [redacted] ជនោ- [redacted] ចំណាប់- [redacted] រតនា [redacted] រតនៈ- [redacted] ធីតា- [redacted] ម៉ូនីកា- និង [redacted] ហ៊ីម ។

៤.ប្រាក់ប្រដាប់ក្ដីជាបន្ទុកដើមចោទ និងចុងចម្លើយ ។

៥.សាលដីកានេះ បញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និងប្រកាសជាសាធារណៈ បើសិទ្ធិប្ដឹងសាទុក្ខរយៈពេល១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ

ហត្ថលេខា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ , ថ្ងៃទី 3 ខែ 12 ឆ្នាំ២០១២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

៤៧០

470

Scanned with CamScanner